**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** **ក្រសួងធនធានទឹក និងឧតុនិយម** **ក្រសួងអភិវឌ្ឍន៍ជនបទ**

# សេចក្ដីប្រកាសព័ត៌មានរួម
# ស្ដីពី
# កិច្ចប្រជុំត្រី-វិស័យលើកទី៤ ស្ដីពីកសិកម្ម-ទឹក-ជនបទ

នាព្រឹកថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម** និង **ឯកឧត្តម ឆាយ ឫទ្ធិសែន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** បានរួមគ្នាដឹកនាំកិច្ចប្រជុំត្រី-វិស័យលើកទី៤ ស្តីពីកសិកម្ម-ទឹក-ជនបទ ដើម្បីពិនិត្យវឌ្ឍនភាពការងារសម្របសម្រួលការអនុវត្តកម្មវិធីគោលនយោបាយអាទិភាព និងសកម្មភាពដែលពាក់ព័ន្ធនឹងសហគមន៍កសិកម្មទំនើប សហគមន៍កសិករប្រើប្រាស់ទឹក និងភូមិគំរូ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ ក្រុមការងារត្រី-វិស័យ កសិកម្ម-ទឹក-ជនបទ លេខាធិការដ្ឋាននិងមន្ត្រីជំនាញនៃក្រសួងទាំង៣។

ក្នុងប្រសាសន៍ស្វាគមន៍ **ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** បានកត់សម្គាល់ពីសមិទ្ធផលជាក់ស្តែង ដែលយន្តការត្រី-វិស័យសម្រេចបានក្នុងពេលកន្លងមក រួមមានការចាប់ផ្តើមអនុវត្តកិច្ចអន្តរាគមន៍រួមគ្នានៅក្នុងសហគមន៍ចំនួន៣ និងការត្រៀមបញ្ចូលសហគមន៍អាទិភាពជាបន្តបន្ទាប់ទៀត នៅក្នុងផែនការសកម្មភាពរយៈពេលវែងរបស់ខ្លួន។ សម្រាប់**ឯកឧត្តមរដ្ឋមន្ត្រី** យន្តការត្រី-វិស័យបានប្រែក្លាយពីគំនិតផ្តួចផ្តើមមួយ ទៅជាយន្តការអចិន្ត្រៃយ៍ ដើម្បីសម្របសម្រួលផែនការអភិវឌ្ឍន៍យូរអង្វែងរវាងវិស័យទាំង៣ ស្របតាមអភិក្រម "**ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ**" សំដៅគាំទ្រដល់ការលើកកម្ពស់ជីវភាពប្រជាកសិករនៅទីជនបទ និងការអភិវឌ្ឍនៅតាមសហគមន៍មូលដ្ឋាន។

**ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម** បានសម្តែងការសាទរចំពោះលទ្ធផលការងារត្រី-វិស័យ ដែលសម្រេចបានគួរជាទីកត់សម្គាល់ ហើយ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានបញ្ជាក់អះអាងផងដែរពីការខិតខំប្រឹងប្រែងរបស់ក្រសួងក្នុងការបន្តពង្រឹងនិងលើកកម្ពស់សមិទ្ធកម្ម ដើម្បីចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់ការងារត្រី-វិស័យ ជាពិសេសការលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ចវិស័យកសិកម្ម តាមរយៈ

ការកសាងអាងស្តុកទឹក ប្រព័ន្ធជារាសាស្ត្រដែលមានលក្ខណៈពេញលេញ និងការប្រើប្រាស់កម្មវិធីទាញយកព័ត៌មានកសិ-ឧតុនិយម។

**ឯកឧត្តម ឆាយ ឫទ្ធិសែន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** បានសម្តែងការសាទរចំពោះការខិតខំប្រឹងប្រែងនិងកិច្ចសហការរបស់ក្រសួងទាំង៣ ដើម្បីធ្វើឱ្យគំនិតផ្តួចផ្តើមលេចចេញជាផ្លែផ្កា។ **ឯកឧត្តមរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់លើកិច្ចប្រឹងប្រែងរបស់ក្រសួងទាំង៣ ដែលជាសហថាមពលគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ឱ្យកាន់តែមានប្រសិទ្ធភាព។ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានបញ្ជាក់អះអាងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការចូលរួមគាំទ្រ និងអនុវត្តសកម្មភាពការងារត្រី-វិស័យ។

បន្ទាប់ពីស្តាប់របាយការណ៍វឌ្ឍនភាព និងសំណើរបស់ក្រុមការងារត្រី-វិស័យ **ឯកឧត្តមរដ្ឋមន្ត្រី** នៃក្រសួងទាំង៣ បានឯកភាពគ្នាលើចំណុចដូចខាងក្រោម៖

១. ផែនការសកម្មភាព៣ឆ្នាំរំកិល(២០២៥-២០២៧) និងផែនការប្រចាំ២០២៥។

២. ប្រើថវិការាជរដ្ឋាភិបាល(តាមក្រសួង) សម្រាប់គ្រោងសកម្មភាពឆ្នាំ២០២៦ បន្តគាំទ្រដល់សកម្មភាពរបស់សហគមន៍គោលដៅឆ្នាំ២០២៥ និងសហគមន៍ដែលនឹងត្រូវកំណត់បន្ថែមចំនួន៥ទៀត ក្នុងឆ្នាំ២០២៦។

៣. ឯកសារទស្សនទានសម្រាប់រៀបចំ "ការសិក្សារៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រត្រី-វិស័យរយៈពេល ៥ឆ្នាំ (២០២៦-២០៣០)" ដើម្បីតម្រង់ទិសការងារត្រី-វិស័យ និងជាឧបករណ៍ដើម្បីកៀរគរធនធាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនសាធារណជនជ្រាបជាព័ត៌មាន៕

ថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** **ក្រសួងធនធានទឹក និងឧតុនិយម** **ក្រសួងអភិវឌ្ឍន៍ជនបទ**